# បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

ខែមីនា ឆ្នាំ២០២៣

# មាតិកា

**ទំព័រ**


**-ជំពូកទី ១** : *អំពីការិយាល័យបណ្ដោះអាសន្ន និងភារកិច្ច*
*ប្រការ១ ដល់ប្រការ៣*..........................................១-២

**-ជំពូកទី ២** : *អំពីសុពលភាពនៃអាណត្តិរបស់សមាជិកព្រឹទ្ធសភា*
*ប្រការ៤ ដល់ប្រការ៥*.......................................... ៣-៤

**-ជំពូកទី ៣** : *អំពីប្រធាន អនុប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍ និង គណៈកម្មការនានារបស់ព្រឹទ្ធសភា*
*ប្រការ៦ ដល់ប្រការ២៦* ...................................៥-១៧

**-ជំពូកទី ៤** : *អំពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*ប្រការ២៧ ដល់ប្រការ៣០*............................ ១៨-១៩

**-ជំពូកទី ៥** : *អំពីថវិកា*
*ប្រការ៣១*.........................................................២០-២១

**-ជំពូកទី ៦** : *អំពីការពិនិត្យសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង*
*ប្រការ៣២ ដល់ប្រការ៣៥*...........................២២-២៤

**-ជំពូកទី ៧** : *អំពីរបៀបវារៈប្រជុំ*
*ប្រការ៣៦ ដល់ប្រការ៣៧* ...................................២៥

**-ជំពូកទី ៨** : *អំពីរបៀបប្រជុំ*
*ប្រការ៣៨ ដល់ប្រការ៥៦*........................... ២៦-៣៤

**-ជំពូកទី ៩ :** អំពីការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងក្នុងពេលប្រជុំព្រឹទ្ធសភា
ប្រការ៥៧ថ្មី ដល់ប្រការ៦០ថ្មី..................... ៣៥-៣៦
**-ជំពូកទី ១០:** អំពីការបញ្ចេញមតិ
ប្រការ៦១ ដល់ប្រការ៦៧ ........................... ៣៧-៤០
**-ជំពូកទី ១១:** អំពីការរក្សាសេចក្តីស្ងប់ស្ងាត់ក្នុងពេលប្រជុំ
ប្រការ៦៨ ដល់ប្រការ៧០..................................... ៤១
**-ជំពូកទី ១២:** អំពីការឈប់ ឬការខានមកប្រជុំ
ប្រការ៧១ ដល់ប្រការ៧៥........................... ៤២-៤៤
**-ជំពូកទី ១២(ស្ទួន):** អំពីការចូលរួមរបស់សមាជិកព្រឹទ្ធសភាក្នុងសកម្មភាពការងាររបស់ព្រឹទ្ធសភា
ប្រការ៧៥ (ស្ទួន)........................................... ៤៥
**-ជំពូកទី ១៣ថ្មី :** អំពីវិន័យ និងកាតព្វកិច្ចក្រមសីលធម៌
ប្រការ៧៦ ដល់ប្រការ៨១ថ្មី ......................... ៤៦-៤៩
**-ជំពូកទី ១៤:** អំពីការសុំកែប្រែបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
ប្រការ៨២ ដល់ប្រការ៨៣..................................... ៥០
**-ជំពូកទី ១៥:** អវសានប្បញ្ញត្តិ
ប្រការ៨៤ថ្មី.................................................... ៥១

## ជំពូកទី ១
## អំពីការិយាល័យបណ្ដោះអាសន្ន និងភារកិច្ច

**ប្រការ ១**.-

*ព្រឹទ្ធសភាបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ ៦០ថ្ងៃ យ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។*

*ព្រះមហាក្សត្រ ឬព្រះរាជតំណាងទ្រង់ ប្រទាន ឬផ្ដល់កិត្តិយសចំពោះការបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ ។*

*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុកសម្របសម្រួលជាមួយក្រសួងព្រះបរមរាជវាំង ដើម្បីរៀបចំការប្រជុំដំបូងរបស់ព្រឹទ្ធសភា ។*

**ប្រការ ២ ថ្មី**.-

*នៅពេលបើកសម័យប្រជុំដំបូង នៃនីតិកាលនីមួយៗ ព្រឹទ្ធសភាត្រូវចាប់ដំណើរការ ក្រោមអធិបតីភាពនៃប្រធានបណ្ដោះអាសន្ន ១រូបជាសមាជិកព្រឹទ្ធសភាជាប់ឆ្នោត ឬចាត់តាំងអាយុច្រើនជាងគេ ដែលវត្តមាន ហើយឥតមានបណ្ដឹងតវ៉ា ព្រមទាំងសមាជិកព្រឹទ្ធសភាជាប់ឆ្នោត ឬចាត់តាំងចំនួន ៤រូប អាយុតិចជាងគេដែលវត្តមាន ជាលេខាធិការ ដើម្បីជួយប្រធានក្នុងការងារ ។*

*ក្នុងករណីដែលព្រឹទ្ធសមាជិកព្រឹទ្ធសភាខាងលើនេះ មិនអាចអនុវត្តមុខងាររបស់ខ្លួនបាន មុខតំណែងព្រឹទ្ធសមាជិកព្រឹទ្ធសភា ត្រូវ*

ប្រគល់ទៅសមាជិកព្រឹទ្ធសភាដទៃទៀត ដែលមានអាយុច្រើនក្នុងលំដាប់បន្តបន្ទាប់ ។

**ប្រការ ៣**.-

ក្រោមការដឹកនាំរបស់ប្រធានបណ្តោះអាសន្នខាងលើ ព្រឹទ្ធសភាត្រូវចាប់ផ្តើមការងារដូចតទៅ :

ក-ប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។

ខ-បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ។

មិនអាចជជែកពិភាក្សាអ្វីឡើយ នៅក្រោមអធិបតីភាពរបស់ប្រធានបណ្តោះអាសន្ន ។

# ជំពូកទី ២
# អំពីសុពលភាពនៃអាណត្តិរបស់សមាជិកព្រឹទ្ធសភា

**ប្រការ ៤**.-

*ដើម្បីប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ប្រធានបណ្ដោះអាសន្ន ប្រកាសជូនអង្គប្រជុំនូវ :*

- *ឈ្មោះសមាជិកព្រឹទ្ធសភា ២រូប ដែលព្រះមហាក្សត្រទ្រង់បានចាត់តាំង*
- *ឈ្មោះសមាជិកព្រឹទ្ធសភា ២រូប ដែលរដ្ឋសភាបានជ្រើសតាំង*
- *ឈ្មោះសមាជិកព្រឹទ្ធសភាជាប់ឆ្នោតជាស្ថាពរ ដែលគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតបញ្ជូនមក*
- *ឈ្មោះសមាជិកព្រឹទ្ធសភាជាប់ឆ្នោត ដែលមានបណ្ដឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្ដឹងទាំងនោះ។*

*ឈ្មោះសមាជិកព្រឹទ្ធសភាពេញសិទ្ធិទាំងអស់ ត្រូវបិទផ្សាយភ្លាមក្នុងព្រឹទ្ធសភា និងផ្សព្វផ្សាយជាសាធារណៈក្រោយពេលប្រជុំ ។*

*បញ្ជីរាយនាមសមាជិកព្រឹទ្ធសភា ត្រូវចុះផ្សាយក្នុងរាជកិច្ច ។*

*សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ ។*

**ប្រការ ៥.-**

*អាសនៈរបស់សមាជិកព្រឹទ្ធសភាដែលនៅទំនេរយ៉ាងតិច ប្រាំមួយខែ មុនចប់នីតិកាល ដោយហេតុសុំលាលែង បោះបង់ចោលការងារចំនួន ៣ខែ គ្មានការអនុញ្ញាត ដោយទទួលមរណភាព ដោយប្រាសចាកសមាជិកភាពព្រឹទ្ធសភា ឬដោយប្រាសចាកសមាជិកភាពពីគណបក្សនយោបាយ ត្រូវបំពេញជំនួសដោយសមាជិកព្រឹទ្ធសភាថ្មី ចេញពីប្រេកពដើមដែលមានអាសនៈទំនេរនោះ ។*

*ឈ្មោះសមាជិកព្រឹទ្ធសភាចូលជំនួសថ្មី ត្រូវប្រកាសជូនអង្គប្រជុំព្រឹទ្ធសភា ហើយត្រូវបិទផ្សាយក្នុងព្រឹទ្ធសភា និងផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងចុះផ្សាយក្នុងរាជកិច្ច ។*

*សមាជិកព្រឹទ្ធសភាចូលជំនួសថ្មី ត្រូវធ្វើសច្ចាប្រណិធាន មុនពេលចូលកាន់តំណែង ។*

# ជំពូកទី ៣
# អំពីប្រធាន អនុប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភា

**ប្រការ ៦**.-

*ក្រោយពីព្រះមហាក្សត្រ ឬព្រះរាជតំណាងទ្រង់បាន ឬបានបើកនីតិកាលព្រឹទ្ធសភារួចហើយ បើព្រឹទ្ធសភាមានសមាជិកវត្តមានលើសពីពាក់កណ្តាល នៃចំនួនសមាជិកទាំងមូល ព្រឹទ្ធសភាអាចដំណើរការបន្តតាមរបៀបវារៈដូចមានចែងក្នុងប្រការ៣ នៃបទបញ្ជាផ្ទៃក្នុងនេះ ។*

**ប្រការ ៧ ថ្មី**.-

*ប្រធានបណ្តោះអាសន្ន ត្រូវជម្រាបជូនគណបក្សនយោបាយនិងស្ថាប័នមានអាសនៈក្នុងព្រឹទ្ធសភា ដើម្បីឱ្យដាក់បេក្ខជនប្រធាន និងអនុប្រធានព្រឹទ្ធសភា។*

*បេក្ខជនប្រធានព្រឹទ្ធសភា ត្រូវមានសញ្ជាតិខ្មែរពីកំណើតនិងមានសញ្ជាតិខ្មែរតែមួយគត់ ។*

**ប្រការ ៨ ថ្មី**.-

*ការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ត្រូវធ្វើដាច់ដោយឡែកពីគ្នា តាមវិធីបោះឆ្នោតសម្ងាត់ ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។*

ក្នុងករណីបេក្ខជនមានលើសពីមួយរូប បើការបោះឆ្នោតជាលើកទី១ មិនបានទទួលសំឡេងគាំទ្រទេ ត្រូវបោះឆ្នោតជាលើកទី២ ដោយយកបេក្ខជន០១រូប ដែលបានទទួលសំឡេងច្រើនជាងគេ និង/ឬ បេក្ខជន០២រូប ដែលបានទទួលសំឡេងស្មើគ្នាច្រើនជាងគេ មកបោះ-ឆ្នោតឡើងវិញ ។ បើមិនមានបេក្ខជនណាបានទទួលសំឡេងគាំទ្រគ្រប់ចំនួនទៀត ត្រូវបោះឆ្នោតជាលើកទី៣ ដោយយកតែបេក្ខជន ០១រូប ដែលបានទទួលសំឡេងច្រើនជាងគេ មកបោះឆ្នោតឡើងវិញ ។ បើមិនបានសំឡេងគាំទ្រទៀត ប្រធានបណ្តោះអាសន្ន ត្រូវជម្រាបជូនគណបក្សនយោបាយ ឬស្ថាប័នដែលមានអាសនៈនៅព្រឹទ្ធសភា ដើម្បីឱ្យដាក់បេក្ខជនថ្មី ហើយត្រូវបន្តនីតិវិធីបោះឆ្នោតសាឡើងវិញ ។

**ប្រការ ៩ ថ្មី**.-

ប្រធានព្រឹទ្ធសភា ជម្រាបជូនគណបក្សនយោបាយ ឬស្ថាប័នដែលមានអាសនៈនៅព្រឹទ្ធសភា ដើម្បីឱ្យដាក់បញ្ជីបេក្ខជនសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា ។

សមាជិកព្រឹទ្ធសភាមួយរូប អាចឈរជាបេក្ខជនសមាជិកគណៈកម្មការពីរបាន ។

**ប្រការ ១០**.-

ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា ត្រូវធ្វើដាច់ដោយឡែកពីគ្នា តាមវិធីបោះឆ្នោតសម្ងាត់ ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីចាំបាច់ ការបោះឆ្នោតជ្រើសរើសសមាជិកគណៈ-កម្មការនានា អាចធ្វើឡើងច្រើនគណៈកម្មការក្នុងពេលតែមួយបាន ។ សន្លឹកឆ្នោតតាមបញ្ជីរាយនាម និងហិបឆ្នោត ត្រូវធ្វើដាច់ដោយឡែកពីគ្នា ។

បើការបោះឆ្នោតតាមបញ្ជីរាយនាមលើកទី១ មិនបានសម្រេច ការបោះឆ្នោតជាលើកទី២ និងលើកទី៣ ត្រូវធ្វើឡើងចំពោះតែបេក្ខជនដែលពុំទទួលបានសំឡេងគាំទ្រគ្រប់ចំនួនប៉ុណ្ណោះ ។ បើការបោះឆ្នោតជាលើកទី៣ មិនបានសម្រេចទៀត ប្រធានព្រឹទ្ធសភាត្រូវជម្រាបជូនគណបក្សនយោបាយ និងស្ថាប័ន ដែលមានអាសនៈនៅក្នុងព្រឹទ្ធសភា ឱ្យផ្លាស់ប្តូរបេក្ខជន និងធ្វើការបោះឆ្នោតតទៅទៀត ។

**ប្រការ ១១ ថ្មី**.-

ប្រធានព្រឹទ្ធសភាមានភារកិច្ចដូចតទៅ :

ក- ធានាការប្រព្រឹត្តទៅនៃព្រឹទ្ធសភាឱ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ។

ខ- ដឹកនាំអង្គប្រជុំនៃព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ ។

គ- ធានាដឹកនាំការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងឥស្សរជនសម្រាប់មុខតំណែងផ្សេងៗ ដែលកំណត់ដោយច្បាប់ ។

ឃ- ទទួលអាញត្តិច្បាប់ និងសេចក្តីសម្រេចផ្សេងៗ ដែលព្រឹទ្ធសភាបានអនុម័ត ។

ង- ចាត់ចែងបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលបានទទួលទៅគណៈកម្មការ ដើម្បីពិនិត្យសិក្សា និងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា ។

ច- លើកជូនអង្គប្រជុំព្រឹទ្ធសភាសម្រេចអំពីការស្នើសុំចាត់ទុកជាការប្រញាប់ ។

ឆ- បើកអង្គប្រជុំ ផ្អាកពេលប្រជុំ ឬលើកពេលប្រជុំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ ។

ជ- ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ ។

ឈ-ញ៉ាំងឱ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ។

ញ-រក្សាការពារសណ្តាប់ធ្នាប់ក្នុងព្រឹទ្ធសភា ។

ដ- តំណាងព្រឹទ្ធសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ រដ្ឋសភា ឬអាជ្ញាធរសាធារណៈ ។

ឋ- ទាក់ទងជាមួយប្រធានរដ្ឋសភា ដើម្បីរៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា ស្របតាមច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ។

ឌ-ចេញសេចក្ដីសម្រេចចាត់តាំងក្រុមសមាជិកព្រឹទ្ធសភាឱ្យទទួលបន្ទុកការងារផ្សេងៗ ក្រោយពីទទួលបានការឯកភាពពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

ឍ-រ៉ាប់រងការងារអន្តរជាតិរបស់ព្រឹទ្ធសភា ។

**ប្រការ ១២ ថ្មី**.-

អនុប្រធានទាំងពីរជួយធ្វើការប្រធាន ទៅតាមការបែងចែកភារកិច្ចពីប្រធាន ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជំងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្ដីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួសក្នុងឋានៈជាប្រធានស្ដីទី តាមរយៈលិខិតផ្ទេរសិទ្ធិ ។

**ប្រការ ១៣**.-

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមាន :

- ប្រធានព្រឹទ្ធសភា
- អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា

- ប្រធានគណៈកម្មការនានារបស់ព្រឹទ្ធសភា ។

ប្រធានព្រឹទ្ធសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

**ប្រការ ១៤ ថ្មី**.-

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា មានភារកិច្ចដូចតទៅ ៈ

ក- ដឹកនាំ ចាត់ចែង និងពិនិត្យសម្រេចរាល់ការងារសកម្មភាពផ្សេងៗរបស់ព្រឹទ្ធសភា ក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។

ខ- ចាត់ចែងការងាររបស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា ។

គ- រៀបចំរបៀបវារៈនៃពេលប្រជុំព្រឹទ្ធសភានីមួយៗ ។

ឃ- រៀបចំសមាសភាពលេខាធិការពីររូប សម្រាប់សម័យប្រជុំបន្ទាប់ ដើម្បីដាក់ជូនអង្គប្រជុំព្រឹទ្ធសភាអនុម័ត ។

ង- ធានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

ច- ធានាការគ្រប់គ្រង និងការចំណាយថវិកាព្រឹទ្ធសភាឱ្យប្រព្រឹត្តទៅបានត្រឹមត្រូវ តាមការកំណត់ក្នុងច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ឆ- ជានាការផ្តល់គ្រឿងឥស្សរិយយសជូនដល់សមាជិក
ព្រឹទ្ធសភា ។

ជ- ជានាការអនុវត្តវិន័យក្នុងព្រឹទ្ធសភា និងគោលការណ៍ក្រម
សីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ។

ឈ- ពិនិត្យ និងសម្រេចដាក់ទណ្ឌកម្មវិន័យចំពោះសមាជិក
ព្រឹទ្ធសភា ដែលមានកង្វះខាតធ្ងន់ធ្ងរក្នុងការគោរពក្រម-
សីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ។

ញ- លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចលើការស្នើចោទ
ប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនសមាជិកព្រឹទ្ធសភា
ដោយអនុវត្តតាមកឋាខណ្ឌទី២ និងទី៣ មាត្រា១០៤ថ្មី
នៃរដ្ឋធម្មនុញ្ញ ។

ដ- លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចលើការផ្អាកការ
ឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយ ។

ឋ- លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចអំពីការលើក
អភ័យឯកសិទ្ធិសភា ការប្រគល់ជូនវិញនូវអភ័យឯក-
សិទ្ធិសភា ការបោះបង់ចោលការងារ វិសមិតភាព និង
ការប្រាសចាកសមាជិកភាពព្រឹទ្ធសភា ។

**ប្រការ ១៥ ថ្មី.-**

គណៈកម្មការនានារបស់ព្រឹទ្ធសភាមាន :

១- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត ។

២- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ។

៣- គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។

៤- គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ ។

៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ។

៦- គណៈកម្មការនីតិកម្ម និងយុត្តិធម៌ ។

៧- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ។

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី ។

៩- គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

១០- គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុក-
រលួយ ។

**ប្រការ ១៦**.-

គណៈកម្មការនីមួយៗ ត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូប ដោយវិធីបោះឆ្នោតសម្ងាត់ ។

គណៈកម្មការនីមួយៗ មានសមាជិកយ៉ាងតិច ៥រូប ។

**ប្រការ ១៧**.-

គណៈកម្មការនីមួយៗ ត្រូវកំណត់តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនឱ្យស្របនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់ជាធរមាន រួចដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសម្រេច ។

**ប្រការ ១៨**.-

ប្រធានគណៈកម្មការនីមួយៗ មានភារកិច្ចដូចតទៅ :

ក- តំណាងគណៈកម្មការនៅក្នុងអង្គប្រជុំនៃគណៈកម្មាធិការ
អចិន្ត្រៃយ៍ព្រឹទ្ធសភា ។

ខ- ចាត់ចែងការគ្រប់គ្រង និងការងាររដ្ឋបាលទូទៅរបស់គណៈ-
កម្មការ ។

គ- លើកកម្មវិធីការងារ និងចាត់ចែងសកម្មភាពរបស់គណៈ-
កម្មការ ។

ឃ- កោះប្រជុំគណៈកម្មការ និងដឹកនាំកិច្ចប្រជុំទាំងនោះ ។

ង- ចុះហត្ថលេខាលើកំណត់ហេតុប្រជុំរបស់គណៈកម្មការ ។

ច- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្តី-ព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកបំភ្លឺចំពោះមុខគណៈកម្មការ ។

ឆ- អញ្ជើញតំណាងក្រសួងពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ ឬតំណាងសង្គមស៊ីវិល ចូលរួមឱ្យយោបល់លើបញ្ហាផ្សេងៗ ។

ជ- ធានាផ្តល់របាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំ ៦មាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ។

ឈ- ផ្តួចផ្តើមគំនិតរៀបចំសិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេសរបស់គណៈកម្មការ ។

ញ- ធានាការងាររបស់គណៈកម្មការតាមថិរវេលាកំណត់ក្នុងការពិនិត្យឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬការងារផ្សេងៗ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ជូន ។

អនុប្រធាន និងលេខាធិការជួយប្រធានគណៈកម្មការ ក្នុងការសម្រេចភារកិច្ចខាងលើនេះ ។ សមាជិកគណៈកម្មការផ្សេងទៀតបំពេញភារកិច្ចទៅតាមការបែងចែកជាក់ស្តែងក្នុងគណៈកម្មការ ។

**ប្រការ ១៩**.-

ក្នុងករណីចាំបាច់ តាមការផ្តួចផ្តើមគំនិតរបស់ប្រធានព្រឹទ្ធសភា ឬតាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ឬរបស់សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ព្រឹទ្ធសភា អាចសម្រេចបង្កើតគណៈកម្មការពិសេស ដែលមានសមាជិកច្រើន ឬតិចតាមតម្រូវការ សម្រាប់ធ្វើការងារច្បាស់-លាស់ណាមួយរហូតដល់ចប់ ។

**ប្រការ ២០**.-

គណៈកម្មការពិសេស ត្រូវរាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងជូនព្រឹទ្ធសភា ហើយមានសិទ្ធិស្នើសុំជំនួយការ មធ្យោបាយ និងថវិកាសម្រាប់បំពេញការងារ ។

**ប្រការ ២១**.-

គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានារបស់ព្រឹទ្ធសភា មានអាណត្តិស្មើនឹងនីតិកាលរបស់ព្រឹទ្ធសភា ។

កូរ៉ុមសម្រាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ឬគណៈកម្មការពិសេស ត្រូវមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងមូល ។

រាល់ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា និងគណៈកម្មការពិសេស ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល ។

**ប្រការ ២២**.-

ក្នុងករណីដែលប្រធានគណៈកម្មការណាមួយអវត្តមាន អនុប្រធានទទួលជាប្រធានស្ដីទី ។ បើទាំងប្រធាន និងអនុប្រធានអវត្តមាន លេខាធិការគណៈកម្មការទទួលជាប្រធានស្ដីទីរហូតដល់ប្រធាន ឬ អនុប្រធានចូលបំពេញការងារវិញ ។

ប្រធានស្ដីទី មានសិទ្ធិចូលរួមប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បាន តែគ្មានសិទ្ធិអនុម័ត ។

**ប្រការ ២៣**.-

គណៈកម្មការនីមួយៗ អាចស្នើសុំប្រធានព្រឹទ្ធសភា ចាត់តាំងអ្នកជំនាញដែលមិនមែនជាសមាជិកព្រឹទ្ធសភា ឱ្យចូលរួមធ្វើការបាន ។ អ្នកជំនាញនោះ គ្មានសិទ្ធិសម្រេចកិច្ចការរបស់គណៈកម្មការទេ ។

**ប្រការ ២៤**.-

គណៈកម្មការ ឬសមាជិកគណៈកម្មការ ឬសមាជិកព្រឹទ្ធសភាដែលត្រូវបានចាត់ឱ្យទៅបំពេញបេសកកម្មផ្លូវការក្នុងប្រទេស ឬនៅឯបរទេស ត្រូវធ្វើសេចក្ដីរាយការណ៍ពីលទ្ធផលនៃដំណើរបេសកកម្មរបស់ខ្លួន ជូនគណៈកម្មាធិការអចិន្ត្រៃយ៍យ៉ាងយឺតបំផុត ១៥ថ្ងៃ ក្រោយពេលត្រឡប់មកវិញ ។

**ប្រការ ២៥**.-

*ក្នុងករណីដែលគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការនានារបស់ព្រឹទ្ធសភាមានអាសនៈទំនេរ ព្រឹទ្ធសភាត្រូវបោះឆ្នោតបំពេញវិញ ។*

**ប្រការ ២៦**.-

*គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានា មានរបបថវិកាសម្រាប់បំពេញការងារប្រចាំខែ ដែលកំណត់តាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។*

# ជំពូកទី ៤
# អំពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

**ប្រការ ២៧**.-

ព្រឹទ្ធសភាមានអគ្គលេខាធិការដ្ឋានមួយ ទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភា ។ អគ្គលេខាធិការដ្ឋាននេះ ទទួលរ៉ាប់រងរាល់កិច្ចការរដ្ឋបាល សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ប្រធានព្រឹទ្ធសភា ។

**ប្រការ ២៨**.-

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងជាជំនួយការ ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ដែលមានបទពិសោធន៍ក្នុងកិច្ចការសភា ឬរដ្ឋបាលយ៉ាងតិច ១០ឆ្នាំ ហើយដែលមិនមែនជាសមាជិកព្រឹទ្ធសភា និងមិនមែនជាអ្នកដឹកនាំគណបក្សនយោបាយ ។

**ប្រការ ២៩ ថ្មី**.-

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធានព្រឹទ្ធសភា ក្រោយពីបានឯកភាពជាមួយអនុប្រធានទី១ និងអនុប្រធានទី២ ។

អគ្គលេខាធិការ មានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី ។

អគ្គលេខាធិការរង មានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ ។

**ប្រការ ៣០**.-

បុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រធានព្រឹទ្ធសភា ស្របតាមច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ ។

# ជំពូកទី ៥
# អំពីថវិកា

**ប្រការ ៣១**.-

ព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដោយមានការចូលរួមពីតំណាងគណៈកម្មការនានារបស់ព្រឹទ្ធសភា មានភារកិច្ចពិនិត្យ និងលើកយោបល់ក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ព្រឹទ្ធសភា ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីសុំការយល់ព្រមពីគណៈ-កម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាពិនិត្យ សម្រេច ហើយបញ្ជូនសេចក្តីស្នើថវិកានោះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់បញ្ចូលទៅក្នុងគម្រោងថវិកាជាតិ តាមការកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

រាល់ចំណាយថវិការបស់ព្រឹទ្ធសភា ត្រូវមានតម្លាភាព និងធានាផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងសមធម៌ជូនព្រឹទ្ធសភា គណៈ-កម្មការនានារបស់ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា ។

បែបបទចំណាយថវិការបស់ព្រឹទ្ធសភា ត្រូវកំណត់ដោយសេចក្តីសម្រេចប្រចាំឆ្នាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទទួលខុសត្រូវធ្វើរបាយការណ៍ចំណាយថវិកាព្រឹទ្ធសភានៅរាល់ ៦ខែម្តង និងក្នុងរាល់ដំណាច់ឆ្នាំ និង

ដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាពិនិត្យ សម្រេច ក្រោយពីមានការវាយតម្លៃ និងសេចក្តីសន្និដ្ឋានពីគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រមទាំងមានការចូលរួមពីតំណាងគណៈកម្មការនានារបស់ព្រឹទ្ធសភាផង លើកលែងតែរបាយការណ៍ទូទាត់ថវិកាដំណាច់ឆ្នាំ ក្រោយពីគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យសម្រេចហើយ ត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំបញ្ចូលក្នុងសេចក្តីព្រាង-ច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ ។

# ជំពូកទី ៦
# អំពីការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង

**ប្រការ ៣២**.-

*សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ឬបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ស្នើឡើងដោយប្រធានរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវទទួលយកមកពិនិត្យ ព្រមទាំងចាត់បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ ទៅឱ្យគណៈកម្មការមួយ ឬច្រើនពិនិត្យសិក្សាទៅតាមវិស័យជាសមត្ថកិច្ច និងចម្លងចែកជូនគ្រប់សមាជិកព្រឹទ្ធសភា ដោយមានភ្ជាប់សេចក្តីថ្លែងហេតុទៅជាមួយផង ។*

*ក្នុងករណីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំង-ពួងនោះ ពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍ សម្រេចចាត់តាំងគណៈកម្មការណាមួយឱ្យទទួលបន្ទុកធ្វើរបាយការណ៍ ។*

*គណៈកម្មការ ត្រូវសុំយោបល់ពីសមាជិកព្រឹទ្ធសភា (យល់ព្រមកែសម្រួល បដិសេធជាអសារបង់ ភ្ជាប់ដោយការកត់សម្គាល់ និង/ឬ*

អនុសាសន៍) ជាលាយលក្ខណ៍អក្សរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលសមាជិកព្រឹទ្ធសភាម្នាក់ៗបានទទួល។

សមាជិកព្រឹទ្ធសភាគ្រប់រូប មានភារកិច្ចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង មកពិនិត្យសិក្សាលម្អិត ដោយផ្តោតលើខ្លឹមសារទាំងមូល នៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងក្របខណ្ឌភូមិភាគរបស់ខ្លួន ហើយត្រូវជូនយោបល់ ០៣ថ្ងៃ យ៉ាងយូរ មុនគណៈកម្មការប្រជុំពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬបើជាការប្រញាប់ ០១ថ្ងៃ យ៉ាងយូរ មុនគណៈកម្មការប្រជុំពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ។

**ប្រការ ៣៣**.-

ប្រធានគណៈកម្មការ កាលបើពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬសំណើសុំកែសម្រួលរួចហើយ ត្រូវធ្វើលិខិតស្នើសុំមកប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសុំដាក់បញ្ចូលក្នុងរបៀបវារៈនៃអង្គប្រជុំព្រឹទ្ធសភា និងនាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា។

**ប្រការ ៣៤.-**

*សេចក្តីស្នើច្បាប់ ដែលជាការផ្តួចផ្តើមពីសមាជិកព្រឹទ្ធសភា ត្រូវសរសេរជាលាយលក្ខណ៍អក្សរ មានចំណងជើងចែកជាជំពូក ចែកជាមាត្រា ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយ ។*

*សេចក្តីស្នើច្បាប់នេះ ត្រូវបញ្ជូនទៅរដ្ឋសភា ។*

**ប្រការ ៣៥.-**

*ម្ចាស់សេចក្តីស្នើច្បាប់ អាចដកសេចក្តីស្នើច្បាប់នោះចេញបាន ទោះបីសភាកំពុងពិភាក្សាក៏ដោយ ។ ចំពោះសេចក្តីស្នើច្បាប់ដែលស្នើដកចេញ សមាជិកឯទៀត អាចសុំឱ្យសភាពិភាក្សាវិញបាន ។*

# ជំពូកទី ៧
# អំពីរបៀបវារៈប្រជុំ

**ប្រការ ៣៦**.-

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈក្នុងសម័យប្រជុំនីមួយៗ ។ នៅចុងបញ្ចប់នៃការប្រជុំ ប្រធាន ត្រូវអានរបៀបវារៈសម្រាប់ពេលប្រជុំបន្ត ។

**ប្រការ ៣៧**.-

របៀបវារៈមានជាលំដាប់មុនក្រោយដូចតទៅ :

១- បញ្ហាទាំងឡាយ ដែលមានសំណើសុំចាត់ទុកជាការប្រញាប់ ។

២- បញ្ហាទាំងឡាយ ដែលរដ្ឋសភាជូនមកព្រឹទ្ធសភា ។

៣- បញ្ហាទាំងឡាយ ដែលរាជរដ្ឋាភិបាលជូនមកព្រឹទ្ធសភា ។

៤- បញ្ហាទាំងឡាយ ដែលគណៈកម្មការនានាជូនមកព្រឹទ្ធសភា ។

៥- បញ្ហាទាំងឡាយ ដែលសមាជិកព្រឹទ្ធសភាជូនមកព្រឹទ្ធសភា ។

បើក្នុងប្រភេទនីមួយៗមានបញ្ហាជាច្រើននោះ របៀបវារៈនៃបញ្ហាទាំងនោះ ត្រូវរៀបចំតាមលំដាប់កាលបរិច្ឆេទនៃការចូលមកដល់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ ។

# ជំពូកទី ៨
# អំពីរបៀបប្រជុំ

**ប្រការ ៣៨**.-

*អាសនានុក្រមរបស់សមាជិកព្រឹទ្ធសភា ត្រូវរៀបតាមក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ។*

*ក្រុមនីមួយៗ ត្រូវមានសមាជិកយ៉ាងតិច ១០រូប ។ សមាជិកព្រឹទ្ធសភា ១រូប អាចចូលជាសមាជិកក្រុមបានតែមួយប៉ុណ្ណោះ ។ ក្រុមនីមួយៗ ត្រូវមានប្រធាន ១រូប និងអនុប្រធាន ១រូប ។*

*សមាជិកព្រឹទ្ធសភាចាត់តាំងដោយព្រះមហាក្សត្រ ជ្រើសតាំងដោយរដ្ឋសភា និងគណបក្សនយោបាយដែលមានអាសនៈតិចជាងដប់ អាចជ្រើសរើសចូលរួមជាមួយក្រុមណាមួយ តាមការពេញចិត្តរបស់ខ្លួន ។*

*បញ្ជីរាយនាមរបស់ក្រុមសមាជិកព្រឹទ្ធសភា ត្រូវផ្ញើជូនប្រធានព្រឹទ្ធសភា ។*

**ប្រការ ៣៩ ថ្មី**.-

*ការកំណត់ថ្ងៃប្រជុំ ត្រូវធ្វើជាលិខិតផ្ញើទៅជូនសមាជិកព្រឹទ្ធសភា ។ បើមានការកំណត់ដោយផ្ទាល់មាត់ក្នុងពេលប្រជុំ ការកំណត់នេះ ត្រូវធ្វើជាលិខិតជូនទៅសមាជិកព្រឹទ្ធសភា ដែលមិនបានមកប្រជុំ ។*

តាមធម្មតាពេលប្រជុំ ត្រូវកំណត់ ០២ថ្ងៃមុន វៀរលែងតែក្នុងករណីប្រញាប់ ។

ការផ្ញើ ឬបញ្ជូនលិខិតទៅសមាជិកព្រឹទ្ធសភាអាចធ្វើតាមប្រព័ន្ធអេឡិចត្រូនិច ។

**ប្រការ ៤០**.-

លិខិតអញ្ជើញ ត្រូវមានភ្ជាប់ទៅជាមួយនូវរបៀបវារៈប្រជុំ វៀរលែងតែក្នុងករណីប្រញាប់ ។

**ប្រការ ៤១**.-

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក- កូរ៉ុមលើសពីពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬមតិភាគច្រើនដាច់-ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

កូរ៉ុម ត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។

បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ៣០នាទី ក្រោយពេលកំណត់ចាប់ផ្តើមការប្រជុំ ប្រធានព្រឹទ្ធសភាត្រូវលើកពេលប្រជុំ ។

**ប្រការ ៤២ ថ្មី**.-

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា មានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ ។ កំណត់ហេតុទាំងអស់ ត្រូវតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋានព្រឹទ្ធសភា ។

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើក្នុងសាលប្រជុំរបស់ព្រឹទ្ធសភាដោយផ្ទាល់ និងអាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច តាមបែបនិម្មិត និងពាក់កណ្តាលនិម្មិត ។

ព្រឹទ្ធសភាអាចកោះប្រជុំជាសម្ងាត់បាន តាមសំណើសុំពីប្រធានព្រឹទ្ធសភា ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ឬពីព្រះមហាក្សត្រ ឬពីប្រធានរដ្ឋសភា ឬពីនាយករដ្ឋមន្ត្រី ។

កាលបើព្រឹទ្ធសភាសម្រេចថា ត្រូវប្រជុំជាសម្ងាត់ ប្រធានព្រឹទ្ធសភា និងលេខាធិការសម័យប្រជុំមើលឱ្យច្បាស់ជាមុនសិនថា ពិតជាគ្មានមនុស្សដទៃក្រៅពីសមាជិកព្រឹទ្ធសភា លេខាធិការ និងឥស្សរជនដែលព្រឹទ្ធសភាត្រូវការចាំបាច់នៅក្នុងសាលប្រជុំ ។

ក្នុងករណីប្រជុំជាសម្ងាត់ នៅមុនពេលបិទការប្រជុំ ព្រឹទ្ធសភាត្រូវអនុម័តថា អនុញ្ញាត ឬមិនអនុញ្ញាតឱ្យបោះផ្សាយកំណត់ហេតុប្រជុំ ។

**ប្រការ ៤៣**.-

ការប្រជុំព្រឹទ្ធសភា អាចប្រព្រឹត្តទៅបានលុះត្រាមានប្រធានដឹកនាំ ។

ក្នុងពេលប្រជុំណាមួយ បើប្រធាន និងអនុប្រធានព្រឹទ្ធសភាមិននៅ ដោយមានហេតុការណ៍អ្វីជាពិសេស ព្រឹទ្ធសភាត្រូវផ្អាកការប្រជុំជាបណ្ដោះអាសន្ន ។

**ប្រការ ៤៤**.-

បើមានបញ្ហាត្រូវថ្លែងជម្រាបព្រឹទ្ធសភា ប្រធានព្រឹទ្ធសភា ត្រូវថ្លែងមុនចាប់ផ្ដើមរបៀបវារៈ ។

**ប្រការ ៤៥**.-

ដំណើរការប្រជុំត្រូវធ្វើតាមរបៀបវារៈ វៀរលែងតែក្នុងពេលប្រជុំខ្លះ ដែលអង្គប្រជុំសម្រេចផ្សេងពីនេះ ។

មុនចាប់ផ្ដើមសម័យប្រជុំ ព្រឹទ្ធសភាអនុម័តរបៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំ ។

**ប្រការ ៤៦**.-

*លេខាធិការសម័យប្រជុំ ជួយប្រធានព្រឹទ្ធសភាលើកិច្ចការដូចតទៅ :*

- *ពិនិត្យកូរ៉ុមសម្រាប់ប្រជុំ និងនៅពេលអនុម័ត*
- *រៀបចំការបោះឆ្នោត*
- *រាប់ចំនួនសំឡេងអនុម័ត*
- *ចុះហត្ថលេខាលើកំណត់ហេតុអង្គប្រជុំ*
- *បំពេញកិច្ចការផ្សេងៗទៀត តាមសេចក្ដីណែនាំរបស់ប្រធានព្រឹទ្ធសភា ។*

**ប្រការ ៤៧**.-

*តំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលមកការពារ ត្រូវមានវត្តមាននៅក្នុងសាលប្រជុំ តាមសេចក្ដីអញ្ជើញរបស់ប្រធានព្រឹទ្ធសភា ។*

*ឈ្មោះអ្នកមកការពារសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង ត្រូវជូនមកប្រធានព្រឹទ្ធសភាមុនពេលចាប់ផ្ដើមការពិភាក្សា និងអនុម័ត ។*

*សហការីជាអ្នកជំនាញដែលមកជាមួយអាចបំភ្លឺជូនអង្គប្រជុំបាន បើសិនមានការអនុញ្ញាតពីប្រធានព្រឹទ្ធសភា ។*

**ប្រការ ៤៨**.-

ប្រធានព្រឹទ្ធសភា អាចលើកពេលប្រជុំបាន បើយល់ឃើញថា ជាការមានប្រយោជន៍ ឬជាការចាំបាច់ ។

**ប្រការ ៤៩**.-

លេខាធិការសម័យប្រជុំ ត្រូវកត់ឈ្មោះសមាជិកព្រឹទ្ធសភាក្នុងក្រុមនីមួយៗ ដែលសុំបញ្ចេញយោបល់ជាលំដាប់មុនក្រោយ ហើយបញ្ជូនទៅប្រធានព្រឹទ្ធសភា ។

**ប្រការ ៥០**.-

ក្នុងការជជែកពិភាក្សាបញ្ចេញយោបល់ ប្រធានត្រូវឱ្យនិយាយឆ្លាស់គ្នា គឺអ្នកគាំទ្រនិយាយម្តង អ្នកមិនគាំទ្រនិយាយម្តង ។

តំណាងក្រុមសមាជិកព្រឹទ្ធសភា ដែលបានអនុញ្ញាតឱ្យបញ្ចេញយោបល់ ត្រូវមានយោបល់តែអំពីរឿងដែលកំពុងពិភាក្សា ។ បើបញ្ចេញយោបល់ចាកប្រធាន ប្រធានព្រឹទ្ធសភាត្រូវរំលឹកឱ្យចូលមកក្នុងប្រធានបទវិញ ។

ក្នុងករណីដែលវាគ្មិនរូបនោះ នៅតែចចេសបញ្ចេញយោបល់ចាកប្រធានដដែលនោះ ប្រធានត្រូវបញ្ឈប់មិនឱ្យនិយាយបន្តទៅទៀត ។

**ប្រការ ៥១**.-

ជាគោលការណ៍ រយៈពេលបញ្ចេញយោបល់សម្រាប់ក្រុមសមា-ជិកព្រឹទ្ធសភានីមួយៗ ត្រូវមានកំណត់ ។ សមាជិកព្រឹទ្ធសភាតំណាងក្រុម

នីមួយៗ ដែលចុះឈ្មោះសុំបញ្ចេញយោបល់អាចនិយាយបាន ២០នាទីយ៉ាងយូរ ។ សមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗ ដែលគ្រាន់តែសុំឆ្លើយតបនិយាយបានត្រឹមតែ ៥នាទី ប៉ុណ្ណោះ ។

បើប្រធានព្រឹទ្ធសភាយល់ឃើញថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សា នោះប្រធានព្រឹទ្ធសភា អាចអនុញ្ញាតបន្ថែមពេលឱ្យនិយាយបាន ១០នាទីទៀត ។ ការបន្ថែមនេះ អាចឱ្យបន្តបានពីរដងក្នុងប្រធានបទតែមួយ ។

សមាជិកព្រឹទ្ធសភាក្នុងក្រុមជាមួយ មានសិទ្ធិសុំបញ្ចេញមតិបន្ថែម ក្នុងប្រធានបទដដែល និងក្នុងរយៈពេលដែលនៅសល់ពីការកំណត់ខាងលើ ។

**ប្រការ ៥២**.-

បទប្បញ្ញត្តិអំពីការសុំចុះឈ្មោះបញ្ចេញយោបល់ និងអំពីការកំណត់រយៈពេលបញ្ចេញយោបល់ប្រើសម្រាប់តែសមាជិកព្រឹទ្ធសភា មិនប្រើសម្រាប់តំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សេចក្តីស្នើច្បាប់ ឬអ្នកជំនាញការពារសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះទេ ។

**ប្រការ ៥៣**.-

*ហាមបញ្ចេញយោបល់កាត់អ្នកដទៃ បញ្ចេញយោបល់វាយប្រហារបុគ្គល ឬសម្តែងអាការៈផ្សេងៗ ដែលនាំឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។*

**ប្រការ ៥៤**.-

*បើមានការជ្រួលច្របល់ក្នុងពេលប្រជុំ ហើយប្រធានហាមពុំស្តាប់ ប្រធានអាចលើកពេលប្រជុំ ដោយក្រោកដើរចេញពីសាលប្រជុំ ។*

**ប្រការ ៥៥**.-

*ក្នុងចន្លោះសម័យប្រជុំ សមាជិកព្រឹទ្ធសភាក៏ដូចជាសមាជិកគណៈកម្មការនានា ត្រូវបំពេញការងារជាប្រក្រតីក្នុងព្រឹទ្ធសភា និងចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិភាគ ។*

*សម្រាប់ដំណើរចេញទៅបរទេសចាប់ពី ៣ថ្ងៃឡើងទៅ ត្រូវមានច្បាប់អនុញ្ញាតពីប្រធានព្រឹទ្ធសភា ។ ក្នុងករណីដូចនេះ ការអនុញ្ញាតច្បាប់ចេញទៅបរទេស ត្រូវអនុវត្តតាមកឋាខណ្ឌទី២ ប្រការ ៧១ ជំពូកទី ១២ នៃបទបញ្ជាផ្ទៃក្នុងនេះ ។*

**ប្រការ ៥៦**.-

*គណៈកម្មការនានា ត្រូវមានរបាយការណ៍តាមវិស័យជាសមត្ថ-កិច្ចរបស់ខ្លួន និងសមាជិកព្រឹទ្ធសភា ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរពីសកម្មភាពរៀងៗខ្លួន ក្នុងចន្លោះសម័យប្រជុំជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីបូកសរុបរាយការណ៍ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ។*

## ជំពូកទី ៩
## អំពីការពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងក្នុងពេលប្រជុំព្រឹទ្ធសភា

**ប្រការ ៥៧ ថ្មី**.-

*ការពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង ព្រឹទ្ធសភាត្រូវអនុវត្តតាមបទប្បញ្ញត្តិមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។*

*ជាទូទៅ ការពិនិត្យហើយឱ្យយោបល់ ផ្ដើមឡើងដោយការបង្ហាញរបាយការណ៍របស់គណៈកម្មការ ការឆ្លើយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល ម្ចាស់សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង ។*

**ប្រការ ៥៨**.-

*តំណាងក្រុមសមាជិកព្រឹទ្ធសភានីមួយៗ មានយោបល់ភ្លាមអំពីការយល់ព្រម ឬមិនយល់ព្រម ឬបញ្ចេញយោបល់ជំទាស់ បន្ទាប់ពីគណៈកម្មការបានបង្ហាញពីជំហរខ្លួនក្នុងរបាយការណ៍ ក្នុងថិរវេលាមិនឱ្យលើសពីការកំណត់នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។*

*តំណាងរាជរដ្ឋាភិបាល ឬម្ចាស់សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬគណៈកម្មការ ត្រូវឆ្លើយបំភ្លឺចំពោះយោបល់របស់សមាជិកព្រឹទ្ធសភាដែលបានលើកឡើង ។*

**ប្រការ ៥៩**.-

ក្រោយពីបានស្តាប់ការឆ្លើយបំភ្លឺពីតំណាងរាជរដ្ឋាភិបាល ឬម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង និងគណៈកម្មការប្រធានអង្គប្រជុំ ត្រូវលើកជូនអង្គប្រជុំអនុម័ត (យល់ព្រមដោយឥតកែប្រែ ទទួលយកយោបល់សុំកែសម្រួល ឬទទួលយកយោបល់សុំបដិសេធជាអសារបង់) ។

**ប្រការ ៦០ ថ្មី**.-

អង្គប្រជុំត្រូវពិនិត្យហើយឱ្យយោបល់យល់ព្រមលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ដោយឥតកែប្រែ ប្រសិនជាគ្មានយោបល់សុំកែសម្រួល និងបដិសេធជាអសារបង់ ។

បើអង្គប្រជុំទទួលយកយោបល់សុំកែសម្រួល សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ត្រូវបញ្ជូនការសុំកែសម្រួលជាលាយលក្ខណ៍អក្សរនេះទៅរដ្ឋសភា ដើម្បីពិចារណា ។

បើអង្គប្រជុំទទួលយកយោបល់បដិសេធជាអសារបង់ ក្នុងករណីនេះ ព្រឹទ្ធសភា ត្រូវជូនព័ត៌មានភ្លាមទៅរដ្ឋសភា ។

## ជំពូកទី ១០
## អំពីការបញ្ចេញមតិ

**ប្រការ ៦១**.-

*ក្នុងបញ្ហាទាំងឡាយ ដែលព្រឹទ្ធសភាត្រូវពិនិត្យ ព្រឹទ្ធសភាបញ្ចេញមតិដោយវិធីបីយ៉ាង គឺដោយលើកដៃ ដោយបោះឆ្នោតចំហ ឬដោយបោះឆ្នោតសម្ងាត់ ។*

*ការបញ្ចេញមតិដោយវិធីទាំងបីយ៉ាង អាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ។*

**ប្រការ ៦២**.-

*ចំពោះការបញ្ចេញមតិដោយវិធីលើកដៃ លេខាធិការអង្គប្រជុំជាអ្នករាប់ចំនួនសមាជិកដែលលើកដៃ ។ បើប្រធាន និងលេខាធិការយល់ឃើញថា ការរាប់លទ្ធផលមិនច្បាស់លាស់ទេនោះ ត្រូវឱ្យបញ្ចេញមតិ និងរាប់សាជាថ្មី ។*

**ប្រការ ៦៣**.-

*បើការបញ្ចេញមតិដោយលើកដៃ ដែលបានធ្វើពីរដងហើយនៅតែមិនបានលទ្ធផលច្បាស់លាស់ទេនោះ ត្រូវប្រើវិធីបោះឆ្នោតជាចំហ ។*

វិធីបោះឆ្នោតចំហត្រូវធ្វើដូចតទៅ :

- លេខាធិការអង្គប្រជុំចែកសន្លឹកឆ្នោត រួចកាន់ហិបឆ្នោតដើរប្រមូលយកសន្លឹកឆ្នោតពីសមាជិកព្រឹទ្ធសភា ។ សមាជិកព្រឹទ្ធសភា ត្រូវសរសេរឈ្មោះខ្លួនលើសន្លឹកឆ្នោតនោះ ។ សន្លឹកឆ្នោតមានបីយ៉ាង : សន្លឹកឆ្នោតពណ៌ស សម្គាល់ការព្រម សន្លឹកឆ្នោតពណ៌ខៀវ សម្គាល់ការមិនព្រម និងសន្លឹកឆ្នោតព៌ណសឆ្នូតខៀវ សម្គាល់អនុបវាទ ។
- ក្រោយពីបោះឆ្នោតរួចហើយ លេខាធិការត្រូវរាប់សន្លឹកឆ្នោត ។
- ពេលរាប់សន្លឹកឆ្នោតរួចហើយ ប្រធានព្រឹទ្ធសភាប្រកាសលទ្ធផលជូនអង្គប្រជុំ ។

**ប្រការ ៦៤**.-

វិធីបោះឆ្នោតសម្ងាត់ត្រូវតែប្រើក្នុងការជ្រើសតាំង ការដាក់វិន័យ ការលើកអភ័យឯកសិទ្ធិសភា ការបោះបង់ចោលការងារ ការសម្រេចឱ្យចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ឬការផ្អាកការឃុំខ្លួន ឬការផ្អាកការចោទប្រកាន់សមាជិកព្រឹទ្ធសភា លើកលែងតែមានច្បាប់ចែងខុសពីនេះ ។

**ប្រការ ៦៥**.-

សម្រាប់ការបោះឆ្នោតសម្ងាត់ លេខាធិការអង្គប្រជុំត្រូវចាប់ឆ្នោតរើសសមាជិកប្រាំរូប ក្នុងចំណោមឈ្មោះសមាជិកព្រឹទ្ធសភាវត្តមាន ដើម្បីរៀបចំជាគណៈកម្មការបោះឆ្នោត ។

គណៈកម្មការចាប់ដំណើរការ ដោយណែនាំអំពីរបៀបបោះ-ឆ្នោត និងចែកសន្លឹកឆ្នោតដល់គ្រប់សមាជិកព្រឹទ្ធសភាវត្តមាន ។

ក្រោយពីសមាជិកព្រឹទ្ធសភាបានបោះឆ្នោតរួចហើយ គណៈ-កម្មការត្រូវរាប់សន្លឹកឆ្នោត (យល់ព្រម មិនយល់ព្រម អនុបវាទ មោឃៈ) ហើយរាយការណ៍លទ្ធផលជូនប្រធានព្រឹទ្ធសភាជា លាយលក្ខណ៍-អក្សរ ។

ប្រធានព្រឹទ្ធសភា ប្រកាសលទ្ធផលនៃការបោះឆ្នោតនេះ ។

**ប្រការ ៦៦**.-

ការអនុម័តទាំងឡាយ ត្រូវយកតាមមតិភាគច្រើនដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ។ ក្រៅពីនេះ មតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ត្រូវទុកជាបានការ វៀរលែងតែមានការកំណត់ក្នុងច្បាប់ដោយឡែក ។

**ប្រការ ៦៧**.-

ចំពោះការសម្រេចណា ដែលតម្រូវឱ្យយកមតិភាគច្រើន ដោយប្រៀប បើចំនួនមតិយល់ព្រម និងចំនួនមតិមិនយល់ព្រមស្មើគ្នា ការ

បោះឆ្នោតត្រូវធ្វើម្តងទៀត ។ បើលទ្ធផលនៃការបោះឆ្នោតលើកទី២ នៅតែស្មើគ្នា ការបោះឆ្នោតត្រូវធ្វើជាលើកទី៣ទៀត បើលទ្ធផលនៅតែស្មើគ្នា ត្រូវចាត់ទុកជាព្រឹទ្ធសភាមិនយល់ព្រម ។

## ជំពូកទី ១១
## អំពីការរក្សាសេចក្ដីស្ងប់ស្ងាត់ក្នុងពេលប្រជុំ

**ប្រការ ៦៨**.-

*ប្រធានព្រឹទ្ធសភា មានភារកិច្ចរក្សាការពារមិនឱ្យមានភយន្តរាយខាងក្នុងក្ដី ខាងក្រៅក្ដី ដែលអាចកើតមានឡើងដល់ព្រឹទ្ធសភាជាយថាហេតុ ។ ដើម្បីសម្រេចភារកិច្ចនេះ ប្រធានព្រឹទ្ធសភា មានសិទ្ធិសុំអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងទ័ព ។*

**ប្រការ ៦៩**.-

*ការថែរក្សាសុវត្ថិភាពព្រឹទ្ធសភា ត្រូវធ្វើឡើងដោយប្រធានព្រឹទ្ធសភាក្នុងនាមព្រឹទ្ធសភា ។ ជាគោលការណ៍ ប្រធានព្រឹទ្ធសភាអាចអនុញ្ញាតឱ្យសាធារណជនចូលក្នុងសាលប្រជុំ តាមចំនួនកន្លែងដែលមាន ។ ប៉ុន្តែបើជនណាធ្វើឱ្យរង្អៀស ដោយវិធីណាមួយដល់អង្គប្រជុំ ប្រធានព្រឹទ្ធសភាអាចឱ្យជននោះចេញពីសាលប្រជុំភ្លាម ។*

**ប្រការ ៧០**.-

*ការចែកចាយ ឬការផ្សព្វផ្សាយឯកសារទាំងឡាយ ដែលពុំមែនជាឯកសារផ្លូវការរបស់ព្រឹទ្ធសភា ត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតពីប្រធានព្រឹទ្ធសភា ។*

# ជំពូកទី ១២
# អំពីការឈប់ ឬការខានមកប្រជុំ

**ប្រការ ៧១**.-

សមាជិកព្រឹទ្ធសភា មិនអាចឈប់ក្នុងថ្ងៃបំពេញការងារ ឬក្នុងថ្ងៃប្រជុំព្រឹទ្ធសភា ដោយមិនមានការអនុញ្ញាតពីប្រធានព្រឹទ្ធសភាបានឡើយ ។

ពាក្យសុំច្បាប់ឈប់ក្នុងថ្ងៃបំពេញការងារ ឬក្នុងថ្ងៃប្រជុំ ត្រូវបញ្ជូនមកប្រធានព្រឹទ្ធសភាយ៉ាងយឺតបំផុត ៣ថ្ងៃ មុនថ្ងៃឈប់ លើកលែងតែពាក្យសុំច្បាប់ឈប់ក្នុងថ្ងៃប្រជុំបន្ថយមកនៅត្រឹមតែ ១ថ្ងៃ ។

ក្នុងករណីបន្ទាន់ ត្រូវជូនដំណឹងមកប្រធានព្រឹទ្ធសភា តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ។

**ប្រការ ៧២ ថ្មី**.-

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា មិនអាចខកខានមកប្រជុំ ដោយគ្មានការអនុញ្ញាតពីប្រធានបានឡើយ ។

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភាដែលខានមកប្រជុំ ដោយគ្មានការអនុញ្ញាត ត្រូវទទួល

វិន័យដូចមានចែងក្នុងប្រការ ៧៧, ប្រការ ៧៧ ស្ទួន, ប្រការ ៧៨ ថ្មី, ប្រការ ៧៩ ថ្មី និងប្រការ ៨០ ថ្មី នៃជំពូកទី ១៣ ថ្មី ។

ប្រធានគណៈកម្មការ ត្រូវរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ និងសម្រេចអំពីការដាក់វិន័យខាងលើ ។

**ប្រការ ៧៣**.-

ក្នុងសម័យប្រជុំនីមួយៗ ប្រធានព្រឹទ្ធសភា អាចអនុញ្ញាតឱ្យសមាជិកព្រឹទ្ធសភា ឈប់ក្នុងថ្ងៃបំពេញការងារសរុបបានតែ ១៥ថ្ងៃ ។ តែបើសមាជិកព្រឹទ្ធសភាណាបាន ឈប់ក្នុងថ្ងៃបំពេញការងារគ្រប់ ១៥ថ្ងៃ ក្នុងសម័យប្រជុំនីមួយៗ ហើយចង់ឈប់ក្នុងថ្ងៃបំពេញការងារទៀត ការសុំឈប់នេះ ត្រូវសុំការយល់ព្រមពីព្រឹទ្ធសភាពេញអង្គ ។

ការអនុញ្ញាតច្បាប់ឈប់ក្នុងថ្ងៃបំពេញការងារ ត្រូវគិតតាមលំដាប់លេខរៀងនៃពាក្យសុំ ។ ក្នុងរយៈពេលតែមួយ អាចអនុញ្ញាតច្បាប់ឱ្យឈប់ក្នុងថ្ងៃបំពេញការងារបានយ៉ាងច្រើនបំផុត១៥ ភាគរយនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ការឈប់ក្នុងថ្ងៃបំពេញការងារលើសពីចំនួនថ្ងៃដែលបានអនុញ្ញាត ចំនួនថ្ងៃឈប់លើសនេះ ត្រូវចាត់ទុកថាឈប់គ្មានច្បាប់អនុញ្ញាត ។

**ប្រការ ៧៤**.-

សមាជិកព្រឹទ្ធសភា ដែលឈប់ក្នុងថ្ងៃបំពេញការងារ ដោយមូលហេតុមានជំងឺរយៈពេល ៩ថ្ងៃ ជាប់ៗគ្នា ត្រូវមានសំបុត្រពេទ្យយកមកសម្គាល់ ។ បើគ្មានសំបុត្រពេទ្យមកជាសម្គាល់ ការឈប់ក្នុងថ្ងៃបំពេញការងារ ដោយមូលហេតុមានជំងឺ ត្រូវចាត់ទុកថាឈប់គ្មានច្បាប់អនុញ្ញាត ។

**ប្រការ ៧៥**.-

សមាជិកព្រឹទ្ធសភា ដែលបានទទួលលិខិតអញ្ជើញប្រជុំ ឬបានទទួលការប្រាប់ផ្ទាល់មាត់ ឬបានទទួលដំណឹងតាមគ្រប់មធ្យោបាយផ្សេងៗ ត្រូវចូលប្រជុំតាមការអញ្ជើញ ។

ការមិនចូលប្រជុំតាមការអញ្ជើញ ចាត់ទុកថាជាការខានមកប្រជុំគ្មានការអនុញ្ញាត ។

# ជំពូកទី ១២ (ស្ទួន)
# អំពីការចូលរួមរបស់សមាជិកព្រឹទ្ធសភា
# ក្នុងសកម្មភាពការងាររបស់ព្រឹទ្ធសភា

**ប្រការ ៧៥ (ស្ទួន)**.-

*សមាជិកព្រឹទ្ធសភាគ្រប់រូប មានកាតព្វកិច្ចចូលរួមរាល់សកម្មភាពការងាររបស់ព្រឹទ្ធសភា ប្រកបដោយប្រសិទ្ធភាព ។*

*ត្រូវកាត់ប្រាក់បំណាច់ប្រចាំខែចំនួនហាសិបភាគរយ ចំពោះសមាជិកព្រឹទ្ធសភាដែលអវត្តមានលើសពីមួយភាគបីនៃចំនួនអង្គប្រជុំក្នុងសម័យប្រជុំ ឬនៃចំនួនអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឬនៃចំនួនអង្គប្រជុំគណៈកម្មការនានា ក្នុងអំឡុងពេលសម័យប្រជុំ ឬក្នុងអំឡុងពេលចន្លោះសម័យប្រជុំ ។*

*ត្រូវកាត់ប្រាក់បំណាច់ប្រចាំខែចំនួនមួយខែ ចំពោះសមាជិកព្រឹទ្ធសភាដែលអវត្តមាន លើសពីពាក់កណ្ដាលនៃចំនួនអង្គប្រជុំក្នុងសម័យប្រជុំ ឬនៃចំនួនអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឬនៃចំនួនអង្គប្រជុំគណៈកម្មការនានា ក្នុងអំឡុងពេលសម័យប្រជុំ ឬក្នុងអំឡុងពេលចន្លោះសម័យប្រជុំ ។*

## ជំពូកទី ១៣ ថ្មី
## អំពីវិន័យ និងភាតព្វកិច្ចក្រមសីលធម៌

**ប្រការ ៧៦**.-

*វិន័យយកមកអនុវត្តក្នុងព្រឹទ្ធសភាគឺ :*

*ក- ក្រើនរំលឹក ។*

*ខ- ក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ ។*

*គ- បន្ទោសជាលាយលក្ខណ៍អក្សរ ។*

*ឃ- បន្ទោសជាលាយលក្ខណ៍អក្សរ ហើយឱ្យចេញមួយរយៈពេលពីអង្គប្រជុំ ។*

**ប្រការ ៧៧**.-

*ប្រធានព្រឹទ្ធសភា ជាអ្នកក្រើនរំលឹកសណ្ដាប់ធ្នាប់ ឬក្រើនរំលឹកសណ្ដាប់ធ្នាប់ដោយចុះក្នុងកំណត់ហេតុក្នុងពេលអង្គប្រជុំ ។*

*គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកក្រើនរំលឹក ឬក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ ឬបន្ទោសជាលាយលក្ខណ៍អក្សរចំពោះសមាជិកព្រឹទ្ធសភាដែលអវត្តមានរយៈពេលយូរ ។*

*អង្គប្រជុំព្រឹទ្ធសភា ជាអ្នកបន្ទោសជាលាយលក្ខណ៍អក្សរ ឬបន្ទោសជាលាយលក្ខណ៍អក្សរ ហើយឱ្យចេញពីអង្គប្រជុំមួយ*

រយៈពេល ឬបន្ទោសជាលាយលក្ខណ៍អក្សរ ដោយបិទផ្សាយក្នុងព្រឹទ្ធសភា តាមសេចក្តីស្នើពីប្រធានព្រឹទ្ធសភា ។

**ប្រការ ៧៧** ( **ស្ទួន** ).-

គណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ជួយប្រធានព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ក្នុងការបង្ការ ដោះស្រាយទំនាស់ផលប្រយោជន៍របស់សមាជិកព្រឹទ្ធសភា និងរាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងក្រមសីលធម៌សភា ក្នុងអាណត្តិការងាររបស់សមាជិកព្រឹទ្ធសភា និងក្នុងដំណើរការការងាររបស់ព្រឹទ្ធសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រកាសទណ្ឌកម្មវិន័យភ្ជាប់ដោយមូលហេតុ ចំពោះសមាជិកព្រឹទ្ធសភាណាមួយ ដែលមានកង្វះខាតធ្ងន់ធ្ងរ ក្នុងការគោរពក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា តាមសំណើរបស់គណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា បន្ទាប់ពីការជូនសក្ខីកម្មជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់របស់សមាជិកព្រឹទ្ធសភាសាមី ឬតំណាង ។

**ប្រការ ៧៨ ថ្មី**.-

*វិន័យក្រើនរំលឹក យកទៅអនុវត្តចំពោះសមាជិកព្រឹទ្ធសភាដែលប្រព្រឹត្តខុស ដូចតទៅ :*

- *ក្នុងអង្គប្រជុំ សមាជិកព្រឹទ្ធសភា ឬវាគ្មិនណាដែលធ្វើឱ្យខូចសណ្តាប់ធ្នាប់ និងប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិប្រការ៥៣ ជំពូកទី៨ នៃបទបញ្ជាផ្ទៃក្នុងនេះ*
- *ក្នុងអង្គប្រជុំ សមាជិកព្រឹទ្ធសភាដែលប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិប្រការ៧០ ជំពូកទី១១ នៃបទបញ្ជាផ្ទៃក្នុងនេះ*
- *សមាជិកព្រឹទ្ធសភា ដែលប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិកឋាខណ្ឌទី១ ប្រការ៧១ ជំពូកទី១២ នៃបទបញ្ជាផ្ទៃក្នុងនេះ*
- *សមាជិកព្រឹទ្ធសភា ដែលប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិប្រការ៧៤ ប្រការ៧៥ ជំពូកទី១២ នៃបទបញ្ជាផ្ទៃក្នុងនេះ ។*

**ប្រការ ៧៩ ថ្មី**.-

*វិន័យក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ យកទៅអនុវត្តចំពោះសមាជិកព្រឹទ្ធសភា ដែលបានទទួលការក្រើនរំលឹកសណ្តាប់ធ្នាប់ម្តងហើយ ហើយនៅតែប្រព្រឹត្តខុសដដែលទៀតនៅក្នុងពេលប្រជុំតែមួយ ។*

**ប្រការ ៨០ ថ្មី**.-

វិន័យបន្ទោសជាលាយលក្ខណ៍អក្សរ យកទៅអនុវត្តចំពោះសមាជិកព្រឹទ្ធសភា ដែលប្រព្រឹត្តខុស ដូចតទៅ :

- ក្នុងអង្គប្រជុំ សមាជិកព្រឹទ្ធសភាដែលបង្កឱ្យមានការជ្រួលច្របល់ក្នុងសាលប្រជុំ
- ក្នុងអង្គប្រជុំ សមាជិកព្រឹទ្ធសភាដែលជេរប្រមាថ មើលងាយ ឬបង្កជម្លោះ ឬគំរាមកំហែងសមាជិកព្រឹទ្ធសភាឯទៀត ។

វិន័យបន្ទោសជាលាយលក្ខណ៍អក្សរ ត្រូវបានប្រកាសផ្សាយជាសាធារណៈនូវសម្រង់កំណត់ហេតុបន្ទោសនេះ ។

**ប្រការ ៨១ ថ្មី**.-

វិន័យបន្ទោសជាលាយលក្ខណ៍អក្សរ ហើយឱ្យចេញមួយរយៈ-ពេលពីអង្គប្រជុំ យកទៅអនុវត្តចំពោះសមាជិកព្រឹទ្ធសភា ដែលបង្កឱ្យមានអំពើហឹង្សា ជេរប្រមាថមើលងាយព្រឹទ្ធសភា ប្រធានព្រឹទ្ធសភា ឬប្រមាថមើលងាយព្រះមហាក្សត្រ ក្នុងអង្គប្រជុំ ។

វិន័យបន្ទោសជាលាយលក្ខណ៍អក្សរ ហើយឱ្យចេញមួយរយៈ-ពេលពីអង្គប្រជុំ ត្រូវបានប្រកាសផ្សាយជាសាធារណៈនូវសម្រង់កំណត់ហេតុបន្ទោសនេះ និងហាមមិនឱ្យចូលរួមក្នុងសម័យប្រជុំព្រឹទ្ធសភាចំនួន ៣ពេល ជាបន្តបន្ទាប់ ។

# ជំពូកទី ១៤
# អំពីការសុំកែប្រែបទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា

**ប្រការ ៨២**.-

*បទបញ្ញាផ្ទៃក្នុងនេះនឹងកែប្រែបាន លុះត្រាតែមានសេចក្ដីស្នើសុំពីសមាជិកព្រឹទ្ធសភាមួយភាគបួនយ៉ាងតិច នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ហើយត្រូវបានអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។*

*បទបញ្ញាផ្ទៃក្នុងដែលសុំកែប្រែ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងហេតុ និងបញ្ជីហត្ថលេខីនៃម្ចាស់សំណើ ហើយត្រូវផ្ញើជូនប្រធានព្រឹទ្ធសភា ។*

**ប្រការ ៨៣**.-

*ប្រធានព្រឹទ្ធសភា ត្រូវបញ្ជូនបទបញ្ញាផ្ទៃក្នុងដែលសុំកែប្រែនេះទៅគណៈកម្មការនីតិកម្ម និងយុត្តិធម៌ ឬគណៈកម្មការពិសេសដែលព្រឹទ្ធសភាបង្កើតឡើង ដើម្បីពិនិត្យ និងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា ។*

# ជំពូកទី ១៥
# អវសានប្បញ្ញត្តិ

**ប្រការ ៨៤ ថ្មី.-**

មុនចាប់ផ្តើមការងាររបស់ខ្លួន ក្នុងសម័យប្រជុំលើកទី១ នៃនីតិកាលនីមួយៗ ព្រឹទ្ធសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវនៅជាធរមានរហូតដល់មានបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាថ្មីមកជំនួស ។

# កំណត់សម្គាល់

# កំណត់សម្គាល់

បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជានីតិកាលទី៣ បានអនុម័តនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ នាសម័យប្រជុំលើកទី១ ហើយត្រូវបានប្រកាសឱ្យប្រើដោយសេចក្ដីសម្រេចលេខៈ ០១៧/០៨១២/ពស/សរ.ព ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ ត្រូវបានធ្វើវិសោធនកម្ម ចំនួន ០៣លើក ដូចតទៅ ៖

**លើកទី១** : វិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវបានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយត្រូវបានប្រកាសឱ្យប្រើដោយសេចក្ដីសម្រេចលេខៈ ០៩១/០៩១៤/ពស/សរ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤ ។

**លើកទី២** : វិសោធនកម្មប្រការ៩ ប្រការ១១ ប្រការ១២ ប្រការ១៤ ប្រការ៧៨ ប្រការ៧៩ ប្រការ៨០ ប្រការ៨១ និងជំពូកទី១៣ ព្រមទាំងបន្ថែមជំពូកទី១២ (ស្ទួន) ប្រការ៧៥ (ស្ទួន) និងប្រការ៧៧ (ស្ទួន) នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវបានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ហើយត្រូវបានប្រកាសឱ្យប្រើដោយសេចក្ដី

សម្រេចលេខៈ ០៦៥/០៩១៧/ពស/សរ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ ។

**លើកទី៣** : *វិសោធនកម្មប្រការ ២ ប្រការ ៧ ប្រការ ៨ ប្រការ ២៩ ប្រការ ៣៩ ប្រការ ៤២ ប្រការ ៥៧ ប្រការ ៦០ ប្រការ ៧២ និងប្រការ ៨៤ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវបានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ នាសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤ ហើយត្រូវបានប្រកាសឱ្យប្រើដោយសេចក្តីសម្រេចលេខៈ ០២៥/០៣២៣/ពស/សរ.នវ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ។*